# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ០៩ ខែ មិនា ឆ្នាំ២០១២

## ជប៉ុនផ្តល់ ៣៩,៥០០ ដុល្លារអាមេរិក សម្រាប់គម្រោងកែលម្អ មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុននឹងផ្តល់ទឹកប្រាក់សរុបចំនួន ៣៩,៥០០ ដុល្លាអាមេរិក ដល់អង្គការជនពិការអន្តរជាតិសហព័ន្ធសម្រាប់គម្រោងកែលម្អមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មខេត្តកំពង់ចាម។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយលោក តាស៊ីយ៉ា ម៉ាជីដា ទីប្រឹក្សាស្ថានទូត ជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក ប៊ិនយ៉ាមីនង្វៀង នាយកកម្មវិធីប្រចាំតំបន់នៃអង្គការជនពិការអន្តរជាតិសហព័ន្ធ នៅស្ថានទូតជប៉ុន។

ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការបន្លាស់ទី និងផ្តល់នូវសេវាស្តារលទ្ធភាពពលកម្មឡើងវិញយ៉ាងត្រឹមត្រូវដល់ជនពិការនោះ អង្គការជនពិការអន្តរជាតិសហព័ន្ធ (HIF) នឹងសាងសង់អគារបន្ថែមនិងកែលម្អជម្រាលចេញចូលសម្រាប់គ្រប់អគារព្រមទាំងពង្រីកបន្ទប់ព្យាបាលដោយចលនាក្នុងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មខេត្តកំពង់ចាម។គម្រោងនេះនឹងផ្តល់លទ្ធភាពដល់ជនពិការប្រមាណ៣,០០០នាក់ឲ្យទទួលបាននូវសេវាស្តារលទ្ធភាពពលកម្មឡើងវិញយ៉ាងត្រឹមត្រូវ។ គម្រោងនេះនឹងរួមចំណែកដល់ការកែលម្អជីវភាពរស់នៅ និងភាពម្ចាស់ការក្នុងសង្គមរបស់ជនពិការក្នុងប្រទេសកម្ពុជា។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(*ជំនួយគូសាណូណិ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៤៧លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន ៤៦៧ គម្រោងនៅទូទាំងប្រទេស។




ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៩-៣៣០

អ៊ីមែល: eco.jpn@.pp.mofa.go.jp

គេហទំព័រ: http://www.kh.emb-japan.go.jp